# អនុក្រឹត្យលេខ ៩៧ អនក្រ.បក

## ស្តីពីការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទ ខេត្តបាត់ដំបង ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី០៩ ខែមិនា ឆ្នាំ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧/អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១.-** ត្រូវបានកែសំរួលប្រកាសលេខ ០០៩០ ប្រក.កសក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៨៩ របស់ក្រសួងកិសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទ បំរុងទុកនៅទឹកសាបក្នុងខេត្តបាត់ដំបង ដូចតទៅ :

- លប់ចេញនាទីឡូត៍នេសាទលេខ ០៣ លេខ ០៥ និងលេខ ០៧ ចាប់ពីរដូវនេសាទ ២០០១ ២០០២ តទៅ ។
- កាត់ចេញពីនាទីឡូត៍នេសាទនៃផ្ទៃដែននេសាទក្នុងខេត្តបាត់ដំបង និងកំណត់ព្រំប្រទល់ឡូត៍នេសាទជាថ្មីចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយនេះ ។

តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្ត បាត់ដំបងដែលត្រូវកាត់បន្ថយ

ឯកតា ហិកតា

| ប្រភេទ និង លេខឡូត៍ | ផ្ទៃឡូត៍នេសាទ | ផ្ទៃឡូត៍កាត់ចេញ | ផ្ទៃឡូត៍កាត់ចេញ គិតជាភាគរយ | ផ្ទៃឡូត៍នេសាទ នៅសល់ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |
| ១ | ១១.៦១៥ | ៤៨៥ | ៥.១៧ | ១១.១៣០ | |
| ២ | ៥០.៦២៤ | ៤៩០ | ០.៩៧ | ៥០.១៣៤ | |
| ៣ | ៩.១៩៨ | ៩.១៩៨ | ១០០ | ០ | លប់ចេញ |
| ៤ | ១៣.៨៨៣ | ២.១៥៦ | ១៥.៥៣ | ១១.៧២៧ | |
| ៥ | ៣.៦៥៦ | ៣.៦៥៦ | ១០០ | ០ | លប់ចេញ |
| ៦ | ១២.០៣៩ | ២.០០៣ | ១៦.៦៤ | ១០.០៣៦ | |
| ៧ | ១១.២៥១ | ១១.២៥១ | ១០០ | ០ | លប់ចេញ |
| ៨ | ១៤.២៦៨ | ៨.២៩៦ | ៥៨.១៥ | ៥.៩៧២ | |
| ៩ | ៤.៧៨៤ | ៥៩៣ | ១២.៥០ | ៤.១៩១ | |
| ១០ | ២.៧៧៧ | ៣២១ | ១១.៥៦ | ២.៤៥៦ | |
| ១១ | ៧.៨៩៥ | ៣.៣៥០ | ៤២.៤៤ | ៤.៥៤៤ | |
| ១២ | ៤.៥៥៥ | ២.០២៦ | ៤៤.៤៩ | ២.៥២៨ | |
| សរុប ១២ | ១៥៦.៥៣២ | ៥៣.៨១៤ | ២៩.៩០ | ១០២.៧១៨ | |

មាត្រា ២._ ដែននេសាទដែលបានលប់ និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូនប្រជាពលរដ្ឋប្រកបរបរនេសាទគ្រួសារហាមដាច់ខាតមិនអោយជនណាមួយ ហ៊ុងហែងយកទៅលក់ ឬជួលអោយឯកជនធ្វើអាជីវកម្មផ្ដាច់មុខឡើយ ។

មាត្រា ៣._ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទដើម្បីគ្រប់គ្រងកន្លែងដែលបានលប់និងកាត់ចេញពីនាទីឡូត៍នេសាទនេះ ។

មាត្រា ៤._ រាល់បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនិងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ អភិបាលខេត្ត

បាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៩៨ អនក្រ.បក

## ស្តីពីការផ្ទេរឥណទានថវិកា

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០. ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### សំរេច

**មាត្រា ១.-** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៦៨.៨៥១.០០០ រៀល (ហុកសិបប្រាំបី លានប្រាំបីរយហាសិបមួយពាន់រៀល) ពីជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌) មកជំពូក៣២ (អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ : វិភាគទានអោយអង្គការអន្តរជាតិនានា) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ។